**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៣១/១៣ កអជ.សសរ

រាជធានីភ្នំពេញ ថ្ងៃ ៨ រោច ខែភទ្របទ ឆ្នាំម្សាញ់ ព.ស. ២៥៥៧

ថ្ងៃទី ២៧ ខែកញ្ញា គ.ស. ២០១៣

# សេចក្តីសម្រេច

## ស្តីពី

## របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

# សម្រេច

**ប្រការ ១.-** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងអភិវឌ្ឍន៍ជនបទ សំដៅធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា និងការដឹកនាំកិច្ចការទូទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី ៥ នៃរដ្ឋសភា ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២.-** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ មានតួនាទីដឹកនាំការងាររួមរបស់ក្រសួង ចាត់ចែងបញ្ជារាល់សកម្មភាពរបស់លើគ្រប់វិស័យ និងទទួលបន្ទុកផ្ទាល់លើការងារចាត់តាំង ផ្គត់ផ្គង់ ហិរញ្ញវត្ថុ អធិការកិច្ច និងសវនកម្មផ្ទៃក្នុង។

**ប្រការ ៣.-** រដ្ឋលេខាធិការ÷

១- **ឯកឧត្តម សួស គង់** ទទួលបន្ទុកជារដ្ឋមន្ត្រីស្តីទី ពេលរដ្ឋមន្ត្រីអវត្តមាន តាមរយៈលិខិតប្រគល់សិទ្ធិ និងជួយរដ្ឋមន្ត្រីលើការងារទំនាក់ទំនងសាធារណៈ រដ្ឋបាល បុគ្គលិក ផែនការ ហិរញ្ញវត្ថុ ការងារផ្លូវជនបទ និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច ។

២- **ឯកឧត្តម អ៊ិន ចន្ថា** ជួយរដ្ឋមន្ត្រីលើការងារបណ្តុះបណ្តាល និងស្រាវជ្រាវ។

៣- **ឯកឧត្តមបណ្ឌិត សៅ ជីវ័ន្ត** ជួយរដ្ឋមន្ត្រីលើការងារថែទាំសុខភាពជនបទ។

៤- **ឯកឧត្តម ធ្វើ មេង** ជួយរដ្ឋមន្ត្រីលើការងារផ្គត់ផ្គង់ទឹកជនបទ និងការងារអភិវឌ្ឍន៍សហគមន៍។

៥- **លោកជំទាវ ម៉ាត់ ម៉ារ៉ា** ជួយរដ្ឋមន្ត្រីលើការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ការងារអភិវឌ្ឍន៍ជនជាតិភាគតិច និងការងារយេនឌ័រ ស្ត្រី និងកុមារ។

**ប្រការ ៤.-** អនុរដ្ឋលេខាធិការ÷

១- **ឯកឧត្តមបណ្ឌិត ថេង ចំនួសទ្វារ** ទទួលបន្ទុកជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី និងជួយរដ្ឋមន្ត្រីលើការងាររដ្ឋបាល បុគ្គលិក នីតិកម្ម ព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ។

២- **ឯកឧត្តម ហួត សារឹម** ជួយរដ្ឋមន្ត្រីលើការងារផែនការ ហិរញ្ញវត្ថុ ការងារផ្លូវជនបទ និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។

៣- **ឯកឧត្តម សាន វិសាល**ជួយរដ្ឋមន្ត្រីលើការងារបណ្តុះបណ្តាលនិងស្រាវជ្រាវ។

៤- **ឯកឧត្តម ហាច់ អូម៉ាលី** ជួយរដ្ឋមន្ត្រីលើការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ការងារអង្គការមិនមែនរដ្ឋាភិបាល និងសហប្រតិបត្តិការអន្តរជាតិ។

៥- **ឯកឧត្តម ថោង ពោជ** ជួយរដ្ឋមន្ត្រីលើការងារថែទាំសុខភាពជនបទ។

៦- **ឯកឧត្តម ម៉ាន់ ស៊ីមឿន** ជួយរដ្ឋមន្ត្រីលើការងារអភិវឌ្ឍន៍ជនជាតិភាគតិច ។

៧- **ឯកឧត្តម សុខ ម៉េង** ជួយរដ្ឋមន្ត្រីលើការងារអភិវឌ្ឍន៍សហគមន៍ ។

៨- **លោកជំទាវ ទេព បូរ៉ាមីន** ជួយរដ្ឋមន្ត្រីលើការងារផ្គត់ផ្គង់ទឹកជនបទ និង ការងារយេនឌ័រ ស្ត្រី និងកុមារ។

**ប្រការ ៥.-** រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ត្រូវទទួលបន្ទុកអនុវត្តការងារ ឬបេសកកម្មដទៃទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៦.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-** រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**ជា សុផារ៉ា**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី

  “<u>ដើម្បីជូនជ្រាប</u>”
- ដូចប្រការ ៧

  “<u>ដើម្បីអនុវត្ត</u>”
- ឯកសារ-កាលប្បវត្តិ